# សង្គមស៊ីវិលសកម្ម - យុទ្ធសាស្រ្តផ្តោតរួមរបស់អាយស៊ីស៊ី



*សុភាសិតខ្មែរពោលថា៖ «ចង្កឹះមួយបាច់ កាច់មិនបាក់»។ សុភាសិតនេះមានន័យថា ប្រសិនបើជាបុគ្គលម្នាក់ៗ នោះគឺងាយស្រួលក្នុងការទទួលរងគ្រោះណាស់។ ប៉ុន្តែប្រសិនបើនៅជាក្រុមវិញ នោះគឺមានភាពរឹងមាំជាង។ រីឯ នៅក្នុងការងារអភិវឌ្ឍន៍វិញ គឺពិតជាមានការលំបាកណាស់សម្រាប់បុគ្គលម្នាក់ៗឬស្ថាប័នមួយៗ ធ្វើការដោះស្រាយបញ្ហាសង្គម និងសម្រេចបាននូវផលប៉ះពាល់ជាដុំកំភួន។ប៉ុន្តែនៅពេលដែលទាំងអស់គ្នាធ្វើការរួមគ្នា និងមានការរួបរួមគ្នា នោះការផ្លាស់ប្តូរអាចកើតមានឡើងដែលធ្វើឲ្យមានភាពប្រសើរឡើងទៅដល់ប្រជាជនកម្ពុជា។ នេះគឺជាគោលការណ៍នៃបន្ទុំក្រុមជំនុំ ស្ថិតនៅភូមិសាស្រ្តជិតៗគ្នា ដែលគម្រោងវីអាយឌីភី (គម្រោង អភិវឌ្ឍន៍សមាហរណកម្មភូមិ) របស់អង្គការអាយស៊ីស៊ី បានផ្តួចផ្តើមឡើង នៅដើមឆ្នាំ២០១៨ ដើម្បីធ្វើការប្រមូលផ្តុំក្រុមជំនុំជាមួយគ្នា។ បន្ទុំក្រុមជំនុំ នឹងធ្វើឲ្យក្រុមជំនុំកាន់តែរឹងមាំនៅក្នុងវិស័យសង្គមស៊ីវិល ហើយជាមួយគ្នានេះដែរ ក្រុមជំនុំក៏អាចធ្វើការរៀនសូត្រពីគ្នាទៅវិញទៅមក ស្វែងរកដំណោះស្រាយចំពោះបញ្ហាសាសនា និងបញ្ហាសហគមន៍ ហើយជួយគ្នាទៅវិញទៅមក នៅពេលដែលចាំបាច់។*

គម្រោងវីអាយឌីភី បាននិងកំពុងធ្វើការដោយផ្ទាល់ជាមួយក្រុមជំនុំមួយចំនួនអស់រយៈពេលជាង៦ឆ្នាំ ហើយបានពង្រឹងស្មារតីពួកគាត់ឲ្យចូលរួមនៅក្នុងការដោះស្រាយបញ្ហាសង្គម ក៏ដូចជាចូលរួមក្នុងសកម្មភាពអភិវឌ្ឍន៍សហគមន៍របស់ពួកគាត់។ កាលពីឆ្នាំមុន គោលគំនិតនៃបន្ទុំក្រុមជំនុំ ត្រូវបានបង្កើតឡើងពីព្រោះក្រុមការងាររបស់ គម្រោងវីអាយឌីភី មើលឃើញថាក្រុមជំនុំភាគច្រើន អាចមានតម្រូវការលើបណ្តាញក្រុមជំនុំ បន្ទាប់ពីគម្រោងវីអាយឌីភី ត្រូវបានបញ្ចប់ក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខនេះ។ លើសពីនេះទៀត ក្រុមការងាររបស់គម្រោងវីអាយឌីភី មានគោលបំណងពង្រឹងស្មារតីដល់ ក្រុមជំនុំឲ្យពួកគាត់មានភាពជាម្ចាស់ការលើអ្វី ដែលពួកគាត់ធ្វើសម្រាប់សហគមន៍របស់ពួកគាត់ ហើយដើម្បីឲ្យមានការសហការ និងពង្រីកបណ្តាញឲ្យកាន់តែធំនាពេលអនាគត សម្រាប់ការគាំទ្រ និងការប្តេជ្ញាចិត្ត។

បច្ចុប្បន្ននេះ នៅតាមបន្ទុំក្រុមជំនុំ ក្រុមជំនុំនីមួយៗផ្លាស់ប្តូរវេនគ្នាក្នុងការដឹកនាំ ការពិភាក្សាជាក្រុមទៅលើបញ្ហាផ្សេងៗ។ ទោះបីជាយ៉ាងណាក៏ដោយ ក្រុមការងាររបស់គម្រោងវីអាយឌីភី នៅតែបន្តធ្វើការបង្ហាត់ពួកគាត់អំពីរបៀបសម្របសម្រួលកិច្ចប្រជុំ។

រហូតមកដល់ពេលនេះ បន្ទុំក្រុមជំនុំចំនួន០៥ ត្រូវបានបង្កើតឡើងដោយគម្រោងវីអាយឌីភី។ បន្ទុំមួយនៅរាជធានីភ្នំពេញ បន្ទុំចំនួនបីទៀតនៅខេត្តតាកែវ និងបន្ទុំមួយទៀតនៅខេត្តកំពត។ លក្ខណៈដែលគួរឲ្យកត់សម្គាល់អំពីបន្ទុំក្រុមជំនុំទាំងអស់នេះ គឺតាមរយៈការរៀនសូត្រ និងការរួមបញ្ចូលគ្នារវាងក្រុមជំនុំ និងសហគមន៍ តាមរយៈការប្រើប្រាស់យុទ្ធសាស្រ្ត "ស្រូបយក"។ គោលបំណងនៃការប្រើប្រាស់យុទ្ធសាស្រ្តនេះ គឺថាក្រុមជំនុំដែលជាសមាជិក អាចធ្វើការផ្សារភ្ជាប់ទំនាក់ទំនង ហើយអាចធ្វើទស្សនកិច្ចសិក្សាទៅកាន់ក្រុមជំនុំដ៏ទៃទៀតនៅក្នុងបណ្តាញ ដើម្បីធ្វើការរៀនសូត្រ និងទទួលបានការបំផុសគំនិត។ ចំណេះដឹងថ្មីនេះ នឹងត្រូវបាននាំត្រឡប់ទៅក្រុមជំនុំ និងសមាជិករបស់ខ្លួនវិញ ដើម្បីចែកចាយបន្ត។ ឧទាហរណ៍៖ ក្រុមជំនុំមួយនៅភូមិតាឡឹង បានប្រមូលប្រាក់ប្រហែលជា ១២០០០ដុល្លារ តាមរយៈការរៃអង្គាសប្រាក់ ដើម្បីសាងសង់ផ្លូវមួយ នៅក្នុងភូមិ។ ការសាងសង់នេះ ត្រូវបានបញ្ចប់ នៅខែកុម្ភៈ ឆ្នាំ២០១៩។ ក្រោយបានឮអំពីសមិទ្ធផលដ៏អស្ចារ្យមួយនេះហើយ ក្រុមជំនុំ នៅក្នុងភូមិព្រីស ចង់ទៅធ្វើទស្សកិច្ចសិក្សា និងរៀនសូត្រពីភូមិតាឡឹង។ ដូច្នេះ អាចនិយាយបានថា យុទ្ធសាស្រ្ត"ស្រូបយក" គឺមានសារៈសំខាន់ក្នុងការរៀនសូត្រពីគ្នាទៅវិញទៅមក រវាងក្រុមជំនុំ/ភូមិមួយ ទៅក្រុមជំនុំ/ភូមិមួយទៀត។

ក្រុមជំនុំ ដែលស្ថិតនៅក្រោមបន្ទុំក្រុមជំនុំទាំង៥នេះ គឺបាននិងកំពុងចូលរួមយ៉ាងសកម្ម ជាមួយនឹងប្រជាជនក្នុងមូលដ្ឋាន និងជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីធានាបានថាគំនិតផ្តួចផ្តើមនៃការអភិវឌ្ឍសហគមន៍របស់ពួកគាត់ គឺត្រូវបានបំពេញតាមតម្រូវការ និងតាមអាទិភាពរបស់សហគមន៍។ ទាំងអស់នេះ គឺមានតំណភ្ជាប់យ៉ាងល្អទៅនឹងយុទ្ធសាស្រ្តផ្តោតទី២របស់អាយស៊ីស៊ី ដែលបានសង្កត់ធ្ងន់ទៅលើការពង្រឹងស្មារតី ទៅដល់អង្គការសង្គមស៊ីវិលថ្មីៗ និងសង្គមស៊ីវិលដែលមានស្រាប់ តាមរយៈការកសាងសមត្ថភាព ការប្រឹក្សាយោបល់ ការប្រមូលផ្តុំ និងការចូលរួម ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍន៍សហគមន៍ និងដោះស្រាយបញ្ហាប្រឈមរបស់ពលរដ្ឋ។

នៅពេលដែលគម្រោងវីអាយឌីភី ត្រូវបានបញ្ចប់ អង្គការអាយស៊ីស៊ី រំពឹងថា នឹងឃើញក្រុមជំនុំ ដែលស្ថិតនៅក្រោមបន្ទុំក្រុមជំនុំទាំងប្រាំនេះ នឹងបន្តមានភាពរឹងមាំក្នុងការចែករំលែកចំណេះដឹង និងបន្តជួយគ្នាទៅវិញទៅមក។ អង្គការអាយស៊ីស៊ី ក៏រំពឹងផងដែរថា ក្រុមជំនុំដែលស្ថិតនៅក្រោមបន្ទុំក្រុមជំនុំទាំងប្រាំនេះ នឹងបន្តធ្វើការយ៉ាងជិតស្និទ្ធជាមួយគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ និងអាជ្ញាធរមូលដ្ឋាន ដើម្បីបន្តកិច្ចការងារអភិវឌ្ឍន៍ភូមិរបស់ពួកគាត់ ក៏ដូចជាការងារលើកកម្ពស់ជីវភាពអ្នកភូមិឲ្យកាន់តែប្រសើរឡើងផងដែរ។

កាលបរិច្ឆេទ៖ មេសា ឆ្នាំ២០១៩